# សេវាចំណតនៃទីក្រុងឡុងប៊ិច

ដីកាចំណត

ដើម្បីបង់ប្រាក់សម្រាប់ដីកាចំណត លោកអ្នកអាចស្វែងរកបាន តាមលេខដីកា ឬ លេខសេចក្តីជូនដំណឹង ។ លេខដីការបស់លោកអ្នក មាននៅលើសំបុត្រច្បាប់ដើម ឬ នៅលើទំព័រសេចក្តីជូនដំណឹង អំពីដីកាចំណត ។ ដើម្បីស្វែងរក តាមលេខដីកា លោកអ្នកត្រូវការទាំង លេខដីកា និងម៉ោងនៃការរំលោភបំពានច្បាប់ ។ ប្រសិនបើលោកអ្នកទទួលបាន ដីកាសរសេរដោយដៃ ដែលមានលេខ 7 ខ្ទង់ សូមដាក់លេខនាំមុខដីកា 00 ។ ដើម្បីស្វែងរក តាមលេខសេចក្តីជូនដំណឹង លោកអ្នកត្រូវការលេខសេចក្តីជូនដំណឹង (លើសេចក្តីជូនដំណឹង អំពីដីកាចំណត) និងលេខកូដតំបន់ 5 ខ្ទង់ ។

**លោកអ្នកនឹងត្រូវបង្វែរទៅកាន់គេហទំព័រសុវត្ថិភាព របស់តតិយភាគី ជាអ្នកលក់**

**ព័ត៌មាន ស្តីពីការទូទាត់យឺតពេល៖**

ការទូទាត់ដែលបានធ្វើ នៅការិយាល័យរបស់យើងខ្ញុំ ក្រោយកាលបរិច្ឆេទផុតកំណត់ នឹងត្រូវពិន័យបន្ថែម សម្រាប់ការទូទាត់យឺតពេល ។ ត្រាសម្គាល់ នឹងមិនត្រូវបានវាយជូននោះទេ ។ ការខកខានមិនជម្រះដីកាដោយការទូទាត់ អាចនាំឱ្យមានការដកហូតការចុះបញ្ជីរថយន្តរបស់លោកអ្នក នៅក្រសួងយានយន្ត និងនាំឱ្យមានការផាកពិន័យបន្ថែម លើការទូទាត់នេះ ។ លើសពីនេះទៅទៀត ម្ចាស់រថយន្តដែលចុះមានបញ្ជី អាចទទួលបានសាលក្រមរដ្ឋប្បវេណី រួមទាំងរងការរាំងស្ទះ ចំពោះពន្ធលើប្រាក់ចំណូលរបស់លោកអ្នក ។

**តើខ្ញុំត្រូវធ្វើអ្វី ប្រសិនបើខ្ញុំមិនមានលេខដីកា ?**

ប្រសិនបើលោកអ្នកគ្មានលេខដីកាទេនោះ សូមទាក់ទងទៅផ្នែកដីកាចំណតរបស់ទីក្រុងឡុងប៊ិច ដែលមានលេខទូរសព្ទ (562)570-6822 ។ ត្រូវមានស្លាកលេខរថយន្តរបស់លោកអ្នក ឬ ឈ្មោះម្ចាស់រថយន្តដែលចុះមានបញ្ជី ក្នុងដៃជាស្រេច ។

**តើដំណើរការនេះមានថ្លៃប៉ុន្មាន ?**

ដំណើរការនេះ ត្រូវបង់ថ្លៃ $1.59 ក្នុងមួយដីកា ទៅតតិយភាគី ជាអ្នកលក់ ។ ទីក្រុងឡុងប៊ិច មិនមែនជាអ្នកទទួលប្រាក់នេះទេ ។

**តើការទូទាត់របស់ខ្ញុំ នឹងត្រូវចំណាយពេលយូរប៉ុណ្ណាដែរ ដើម្បីឱ្យមានបង្ហាញនៅក្នុងប្រព័ន្ធរបស់លោកអ្នក ?**

ដីកានេះ ត្រូវបានធ្វើបច្ចុប្បន្នភាពជាមួយនឹងការទូទាត់របស់លោកអ្នក ភ្លាមៗ បន្ទាប់ពីលោកអ្នកបញ្ចប់ប្រតិបត្តិការដោយជោគជ័យ (ទំព័របង្កាន់ដៃទទួលប្រាក់ មានបញ្ជាក់លេខប្រតិបត្តិការ) ។ ប្រសិនបើលោកអ្នកគិតថា ការទូទាត់នេះមិនត្រូវបានធ្វើឡើយ ដោយជោគជ័យទេនោះ **សូមកុំព្យាយាមធ្វើការទូទាត់ដដែលម្តងទៀត** ។ នេះ គឺដើម្បីឱ្យប្រាកដថា លោកអ្នកមិនធ្វើការទូទាត់ពីរដង ។ សូមទាក់ទងសេវាបម្រើអតិថិជន តាមទូរសព្ទលេខ (562)570-6822 ដើម្បីស្នើសុំជំនួយ ។

**តើខ្ញុំអាចជំទាស់ដីកាដោយរបៀបណាដែរ ?**

# សេវាចំណតនៃទីក្រុងឡុងប៊ិច

មូលហេតុទូទៅ ដែលមិនគាំទ្រដល់ការបដិសេធដីកា មានដូចខាងក្រោម ៖

- ខ្ញុំគ្មានប្រាក់ ដើម្បីទូទាត់នោះឡើយ ។
- ខ្ញុំមិនធ្លាប់ទទួលបានដីកានេះពីមុនមកនោះទេ ។
- ខ្ញុំមិនដឹងថា ខ្ញុំមិនអាចចតរថយន្តនៅទីនោះឡើយ ។

**ការត្រួតពិនិត្យឡើងវិញ ជាបឋម - ដើម្បីជំទាស់ដីកាបង្គាប់ នៅកម្រិតដំបូង (ក្រម ស្ដីពីយានយន្ត នៃរដ្ឋកាលីហ្វ័រញ៉ា លេខ 40215 (ក)**

ប្រសិនបើលោកអ្នកចង់ជំទាស់ដីកា លោកអ្នកត្រូវតែស្នើសុំការត្រួតពិនិត្យឡើងវិញ ក្នុងរយៈពេល 21 ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទចេញដីកា ។ លោកអ្នកអាចចុចប៊ូតុង “ជំទាស់ដីកា” ដើម្បីដាក់សំណើរបស់លោកអ្នកបាន ។ លោកអ្នកក៏អាចភ្ជាប់ជាមួយនូវ ឯកសារ បានរហូតដល់ចំនួនបី (3) ច្បាប់ សម្រាប់ការត្រួតពិនិត្យឡើងវិញនេះផងដែរ ។

**លោកអ្នកនឹងត្រូវបង្វែរឱ្យចូលទៅកាន់គេហទំព័រសុវត្ថិភាពរបស់តតិយភាគី ជាអ្នកលក់**

តាមអ៊ីម៉ែល ៖

ដីកាចំណត
PO Box 22766
Long Beach, CA 90801

ជួបផ្ទាល់ ៖

សាលាក្រុងឡុងប៊ិច
333 West Ocean Blvd, Lobby Level
Long Beach, CA 90802

នៅពេលធ្វើការជំទាស់ លោកអ្នកត្រូវបង្ហាញពីមូលហេតុ សម្រាប់ការស្នើសុំការត្រួតពិនិត្យឡើងវិញលក្ខណៈរដ្ឋបាល និងមានសេចក្ដីចម្លង នៃឯកសារសម្អាងទាំងអស់ (ឯកសារនឹងមិនប្រគល់ជូនវិញទេ) ដែលពាក់ព័ន្ធនឹងដីកា ដូចជា រូបថត ព័ត៌មានអ្នកកាន់លិខិតអនុញ្ញាត របាយការណ៍សាក្សី ។ល។ ដំណើរការនៃការត្រួតពិនិត្យឡើងវិញ លក្ខណៈរដ្ឋបាល ត្រូវអនុវត្ត ដើម្បីជំទាស់ដីកាចំណត ។

**ការជំទាស់ដីការបស់ជនពិការ មាន 2 ជម្រើស**

#1- ជំទាស់ដីកា (CVC 40215) ក្នុងរយៈពេល 21 ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទចេញដីកា ឬ 14 ថ្ងៃ ដោយគិតចាប់ពីថ្ងៃផ្ញើសេចក្ដីជូនដំណឹង អំពីការរំលោភបំពានចំណតខុសច្បាប់ ។

-ឬ-

#2- ជំនួសឱ្យការជំទាស់ ត្រូវបង់ប្រាក់ $25 សម្រាប់ការខកខានមិនបង្ហាញប័ណ្ណជនពិការ ៖ ថ្លៃរដ្ឋបាល (CVC 40226) ដើម្បីដំណើរការលុបចោលដីកា នៅពេលបុគ្គលដែលបានទទួលដីកា អាចបង្ហាញភ័ស្តុតាងថា ខ្លួនមានប័ណ្ណជនពិការដែលមានសុពលភាព នៅពេលទទួលបានដីកានេះ ។ សំណើរនេះ ត្រូវមាន

# សេវាចំណតនៃទីក្រុងឡុងប៊ិច

របាយការណ៍ដែលចុះហត្ថលេខាដោយម្ចាស់ប័ណ្ណ ដែលគាត់មានវត្តមាននៅពេលចេញដីកា សេចក្តីចម្លងនៃប័ណ្ណជនពិការ និងសេចក្តីចម្លងនៃអត្តសញ្ញាណប័ណ្ណរបស់ម្ចាស់ប័ណ្ណ ។

**សវនាការរដ្ឋបាល - ដើម្បីជំទាស់ដីកា នៅកម្រិតទី 2 (CVC 40215 (ខ)**

ប្រសិនបើដីកានេះ ត្រូវបានត្រួតពិនិត្យឡើងវិញ ហើយលោកអ្នកនៅតែមិនពេញចិត្តនឹងលទ្ធផល នោះលោកអ្នកអាចស្នើសុំឱ្យមាន សវនាការរដ្ឋបាល ។ លោកអ្នកនឹងត្រូវបាន តម្រូវឱ្យធ្វើការទូទាត់ទាំងស្រុងនៃដីកាចំណត និងថ្លៃសវនាការរដ្ឋបាល ចំនួន $25.00 ត្រឹមកាលបរិច្ឆេទកំណត់ បញ្ជាក់នៅក្នុងសេចក្តីជូនដំណឹង ដែលបានបង្អាក់ទុក ។ សំណើរសវនាការនេះ អាចធ្វើឡើងតាមអ៊ីនធើណិត សំបុត្រ ឬមកជួបផ្ទាល់ ហើយត្រូវស្នើសុំឱ្យបានមុន កាលបរិច្ឆេទផុតកំណត់ នៅលើលិខិតជូនដំណឹងរបស់លោក-អ្នក ។ សំណើរនេះ ត្រូវបង្ហាញថាតើលោកអ្នកកំពុងស្នើសុំសវនាការ ដោយមកជួបផ្ទាល់ ឬ តាមសំបុត្រ ។ ប្រសិនបើលោកអ្នកស្នើសុំ ដោយមកជួបផ្ទាល់ នោះលោកអ្នកនឹងត្រូវបានជូនដំណឹង អំពីកាលបរិច្ឆេទ និងម៉ោង បើកសវនាការ ហើយលោកអ្នកត្រូវបង្ហាញមុខនៅពេលនោះ ។ ប្រសិនបើលោកអ្នកស្នើសុំសវនាការ តាមសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ នោះលោកអ្នកអាចដាក់ឯកសារបន្ថែម នៅមុនពេលបើកសវនាការ ជូនមន្ត្រីសវនាការសម្រេច ។ លោកអ្នកនឹងទទួលបានការជូនដំណឹង តាមសំបុត្រអំពីសេចក្តីសម្រេច ដោយមន្ត្រីសវនាការ ។ ប្រសិនបើលោកអ្នកមិនពេញចិត្តនឹង សេចក្តីសម្រេចនេះទេ លោកអ្នកអាចមានសិទ្ធិដាក់ពាក្យបណ្តឹងបន្ត ទៅសាលាឧទ្ធរណ៍ ។

**សាលាឧទ្ធរណ៍ - ដើម្បីជំទាស់ដីកា នៅកម្រិតទី 3 (CVC 40230 (ក)**

40230 (ក) ក្នុងរយៈពេល 30 ថ្ងៃប្រតិទិន បន្ទាប់ពីផ្ញើសំបុត្រ ឬ ការបញ្ជូនសេចក្តីសម្រេច ចុងក្រោយដូចមានចែងក្នុងផ្នែករង (ខ) នៃផ្នែក 40215 អ្នកប្តឹងជំទាស់ អាចស្នើសុំការត្រួតពិនិត្យឡើងវិញ ដោយដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ដើម្បីឱ្យមានការជំនុំជម្រះក្តី ពីតុលាការក្រុង ឬ សាលាឧទ្ធរណ៍ នៅក្នុងសង្កាត់ដែលមិនមានតុលាការក្រុង ក្នុងករណីបណ្តឹងនេះត្រូវជំនុំជម្រះសារជាថ្មី លើកលែងតែខ្លឹមងារនៃឯកសាររបស់ ទីភ្នាក់ងារដំណើរការឯកសារ នៅក្នុងរឿងក្តី ត្រូវបានទទួលទុក ជាភ័ស្តុតាង ។ ច្បាប់ចម្លងនៃសេចក្តីជូនដំណឹង អំពីការរំលោភបំពានចំណតនេះ ឬ ប្រសិនបើដីកានេះ ត្រូវបានចេញតាមប្រព័ន្ធអេឡិចត្រូនិក សេចក្តីសង្ខេបត្រឹមត្រូវ និងពិតប្រាកដ ដែលមានព័ត៌មាននៅក្នុងសេចក្តីជូនដំណឹងអំពីការរំលោភបំពានចំណត ត្រូវទទួលយក ជាភ័ស្តុតាង នៃអង្គហេតុដែលបានរៀបរាប់ ។ អ្នកប្តឹងជំទាស់ត្រូវដាក់ច្បាប់ចម្លង នៃសេចក្តីជូនដំណឹង អំពីបណ្តឹងឧទ្ធរណ៍ ដោយផ្ទាល់ ឬ តាមសំបុត្រ លំដាប់ទី 1 ដោយទីភ្នាក់ងារដំណើរការបណ្តឹង ។ ដើម្បីគណនារយៈពេល 30 ថ្ងៃប្រតិទិន ត្រូវអនុវត្តតាមផ្នែក 1013 នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដំណាក់កាលជម្រះក្តី ក្រោមផ្នែករងនេះ ត្រូវកំណត់ត្រឹមសំណុំរឿងរដ្ឋប្បវេណី ។

**គណភ្ជាប់រហ័ស**

**សំណួរចោទសួរជាញឹកញាប់**

**ស្នើសុំទីចំណតជនពិការ**

» ពាក្យស្នើសុំលាបគំនូសផ្លូវពណ៌ក្រហម

» ពាក្យស្នើសុំទីចំណតសម្រាប់ជនពិការ

» ពាក្យស្នើសុំលិខិតអនុញ្ញាតចំណតតាមក្តីប្រាថ្នា

» ពាក្យស្នើសុំសម្រាប់រថយន្តធំលើសកំណត់

**ពាក្យស្នើសុំ**

» លិខិតអនុញ្ញាតចំណតប្រចាំខែ

**ចំណតមាត់ទឹក**

» លិខិតអនុញ្ញាតចំណតឆ្នេរប្រចាំឆ្នាំ

# សេវាចំណតនៃទីក្រុងឡុងប៊ិច

» ចំណតទីជម្រាល

**រថយន្តអគ្គិសនី**
» ទីតាំងស្ថានីយសាកអាគុយ

**ទំនាក់ទំនងយើងខ្ញុំ**
» តើផ្លូវបើកបរ ត្រូវបានហាមឃាត់ឬ ?
ចំណត 72 ម៉ោង ?  - 562.435.6711
» ការិយាល័យបញ្ញូនដីកា - 562.570.6822
» SP+ (Central Parking) - 562.570.8055